# ដំណាំម្ទេស



## ការរៀបចំដីដាំ

- រៀបចំរងទំហំ១ម៉ែត្រ (ត្រូវមានកំពស់ ៣០ ស.មយ៉ាងតិចនៅរដូវវស្សា)
- ពង្រាយជីលាមកគោស្ងួត រឺជីកំប៉ុស្ត៍ និងជីកែងៗពេញរងហើយកាប់ប្រចល់ជាមួយដីអោយសព្វល្អ
- គ្របរងដោយ ចំបើងស.ម បានកំរាស់យ៉ាងតិច ៥ សង់ទីម៉ែត្រ រឺប្រើគំរបជីផ្លាស់ស្ទិក ដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី



## ការបណ្ដុះកូនៈ

ដើម្បីបានកូនម្ទេសដែលមានសុខភាពល្អ យើងត្រូវបណ្ដុះកូននិងកន្ទោងតាមរបៀបខាងក្រោមៈ

- រៀបចំកន្ទោងបណ្ដុះ( ស្លឹកត្នោត រឺស្លឹកចេក )ឬ ថាសបណ្ដុះ
- យកដីមានជីជាតិ( ដីដំបូក )១ភាគជីកំប៉ុស្តិ៍រឺជីលាមកគោដែលរលួយ១ភាគ និងផេះអង្កាម១ភាគ លាយជាមួយគ្នាហើយយកទៅ លីងអោយក្ដៅបំផុត រួចទុកអោយត្រជាក់ទើបដាក់កន្ទោង។ បើមិនលីងល្បាយដីទេ កូនដំណាំងាយមានជំងឺផ្សិតធ្វើឱ្យលួយបាន។



- បណ្ដុះតែ១គ្រាប់ក្នុងមួយកន្ទោង ត្រូវគ្របសំណាញ់សត្វល្អិត និងធ្វើដំបូលគ្រប្រអំពីស្លឹកដូង រឺ សំណាញ់កាត់ពន្លឺនៅរដូវក្ដៅ ។ និងរដូវវស្សាត្រូវធ្វើដំបូលការពារទឹកភ្លៀង ពីព្រោះកូនដំណាំនៅតូចមិនត្រូវការពន្លឺនិងទឹកច្រើនទេ។
- ស្រោចទឹក១ថ្ងៃ មួយដងនៅពេលព្រឹក(បើទុកដីបណ្ដុះស្ងួត គ្រាប់មិនអាចដុះបានទ បើកូនដុះហើយក៏នៅក្រិនដែរ)

កូនដំណាំមានសុខភាពល្អ ជួយអោយដំណាំធំលឿន កាត់បន្ថយការបំផ្លាញពីជំងឺ សត្វល្អិត និងទទួលទិន្នផលបានស្មើគ្នា



## ការដាំកូនម្ទេស

- ត្រូវដាក់កូនម្ទេសអោយត្រូវពន្លឺថ្ងៃពេញចំនួន២ទៅ ៣ ថ្ងៃមុនដាំដើម្បីអោយដើមរឹងមាំល្អហើយផ្សាំនិងអាកាសធាតុខាងក្រៅ
- កូនម្ទេសអាយុបាន ២៥-២៨ថ្ងៃ អាចយកទៅដាំបាន (អាស្រ័យតាមការថែទាំកូន)
- ស្រោចទឹកកូនម្ទេសអោយសើមនៅពេលព្រឹក ទើបយកូនម្ទេសទៅដាំនៅវេលាពេលរសៀល
- យកកូនចេញពីកន្ទោង ឬថាសបណ្ដុះដោយប្រយ័ត្នបំផុតមិនត្រូវអោយដាច់ឬសកូនម្ទេសឡើយ ព្រោះធ្វើអោយកូនម្ទេសអន់បាននៅពេលដាំ
- ត្រូវស្រោចទឹកកូនម្ទេសអោយបានគ្រប់គ្រាន់បន្ទាប់ពីដាំហើយ ជាពិសេសរវាងពី២-៣ អាទិត្យបន្ទាប់ពីដាំកូនហើយ



## ការថែទាំ

- ត្រូវស្រោចទឹកឲ្យបានគ្រប់គ្រាន់នៅពេលព្រឹកជៀសវាងស្រោចទឹកច្រើនពេកធ្វើអោយដីសើមជ្រុលនៅពេលថ្ងៃល្ងាច វាអាចបង្កអោយមានបញ្ហាដល់ ដំណាំបានបន្ទាប់ពីដាំកូនបាន៧-១៥ថ្ងៃ ត្រូវដោតឈើទ្រដែលមានកំពស់៧តឹក ហើយចងដើមម្ទេសទៅនិងឈើទ្រដើម្បីទប់ដើមកុំឲ្យដួល យើងអាចបេះបានយូរ។



ការប្រើប្រាស់ជី ( បើដាក់ជីត្រូវស្រោចទឹក ទើបដំណាំអាចចាប់យកជីបាន)

| ពេលវេលា | ប្រភេទជីប្រើ | កន្លែងដែលត្រូវដាក់ជី |
|---|---|---|
| ដាក់ជីទ្រាប់បាត | ជី អិន ប៉េ កា (១៥. ១៥.១៥)១៣ក្រាម(១ស្លាបព្រាបាយកំពុង)/ដើម ជីលាមកសត្វ ០.៥គីឡូក្រាម/ដើម | ពង្រាយលើរងហើយកាប់ច្របល់នឹងដី |
| ការដាំកូន | ដាំកូនមួយដើម ក្នុងមួយរណ្ដៅ | |
| ២ អាទិត្យបន្ទាប់ពីដាំ | ជីអ៊ុយរ៉េ ២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់កន្លះតឹក |
| ៤ អាទិត្យបន្ទាប់ពីដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់១តឹក |
| ៦ អាទិត្យបន្ទាប់ពីដាំ | ជីប៉ូតាស្យូម១.៩ ក្រាម(១ចុងស្លាបព្រាបាយ)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់១តឹក |
| ៨ អាទិត្យបន្ទាប់ពីដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម | កប់ជីរាក់ៗ ចំងាយពីគល់១តឹកកន្លះ |
| ១១ អាទិត្យបន្ទាប់ពីដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម | កប់ជីរាក់ៗចំងាយពីគល់១តឹកកន្លះ |
| ១៤ អាទិត្យបន្ទាប់ពីដាំ | ជី អិន ប៉េ កា (១៥. ១៥.១៥)២.៥ ក្រាម (១ចុងស្លាបព្រាបាយ)/ដើម | កប់ជីរាក់ៗចំងាយពីគល់១តឹកកន្លះ |

## សត្វល្អិត

ពួកទ្រីបច្រើនជញ្ជក់ត្រួយម្ទេសហើយចម្លងជំងឺធ្វើអោយស្លឹកម្ទេសរួញ។ យើងត្រូវ២សប្ដាហ៍ពិនិត្យមើលទ្រីបនៅតាមត្រួយ បើយើងឃើញមានទ្រីប យើងត្រូវបានថ្នាំសំលាប់វាជាបន្ទាន់ ដើម្បីការពារកុំអោយមានកើតជំងឺបាន។

## ប្រការចងចាំ

កុំប្រើថ្នាំកំចាត់សត្វល្អិតនិងជំងឺឈ្មោះដដែលៗ វាធ្វើអោយសត្វល្អិតនិងជំងឺធន់ទ្រាំជាមួយថ្នាំ ពិបាកកំចាត់នៅពេលក្រោយ។

កុំប្រើថ្នាំពុលលាយចូលគ្នានៅពេលបាញ់ វាធ្វើឲ្យថ្នាំគ្មានប្រសិទ្ធិភាព ហើយសត្វល្អិត ជង្កូវរហ័សស៊ាំនិងថ្នាំពិបាកកំចាត់វាពេលក្រោយ។ ជាពិសេសកុំប្រើថ្នាំដែលមានវណ្ណពណ៌ក្រហម (សញ្ញាក្បាលខ្មោច) វាគ្រោះថ្នាក់ដល់សុខភាពខ្លាំងណាស់។ ដកដើមម្ទេសដចេញភ្លាមបន្ទាប់ពីបញ្ចប់ប្រមូលផលហើយ។ កុំទុកដើមដែលឈប់ប្រមូលផលហើយនៅនឹងក្នុងចំការ។ ពីព្រោះវាជាជំរកសត្វល្អិតនិងជំងឺបំផ្លាញទៅដំណាំផ្សេងទៀតបាន។

## ការប្រមូលផល

ម្ទេសយើងអាចបេះទៅតាមតំរូវការទីផ្សារ អាចជាផ្លែទុំ រឺផ្លែចាស់ក៏បាន៕




ឯកសារពិគ្រោះ

- សៀវភៅណែនាំអំពីបច្ចេកទេសដំណាំបន្លែ, ២០១១
- សៀវភៅណែនាំបច្ចេកទេសកសិករ ផលិតកម្មដំណាំបន្លែ, ២០១៣



សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោម:
លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ដំណាំម្ទេស




សហការផលិតដោយ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងគម្រោង
អភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់-គ្រប់គ្រងវ៉ៃពា ខេត្តសៀមរាប
២០១៣